# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 13-Jun-2011, 15:00
CMS/CFO: Uch Arun

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីរបស់លោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សំណើរលើកទីពីរសុំឲ្យបំពេញកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៣៥

---

ដាក់ដោយ៖

**ក្រុមមេធាវីរបស់លោក នួន ជា៖**

លោក Michiel PESTMAN

លោក Victor KOPPE

លោក Andrew IANUZZI

លោក Jasper PAUW

កញ្ញា Annebrecht VOSSENBERG

កញ្ញា Alejandra CHAPA (កម្មសិក្សាការីច្បាប់)

ផ្ញើជូន៖

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

## I. សេចក្តីផ្តើម

១. អនុលោមតាមវិធាន ២១ និងវិធាន ៣៥ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ("វិធាន") មេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា ("មេធាវីការពារក្តី") សូមដាក់សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរនេះ ("សំណើសុំ") ជូនទៅអង្គជំនុំជម្រះសាលាដំបូង។ ដូចដែលបានលើកឡើងនាពេលថ្មីៗនេះ នៅក្នុងសំណើរបស់ខ្លួនសុំឱ្យបំពេញកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៣៥[១] មេធាវីការពារក្តីបានបង្ហាញពីមន្ទិលសង្ស័យថា មានបុគ្គលមួយចំនួនកំពុងតែជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") នៅក្នុងកិច្ចដំណើរការនីតិវិធីរបស់ខ្លួន។ ការជ្រៀតជ្រែកបែបនេះ គឺជាការគំរាមកំហែងធ្ងន់ធ្ងរដល់ឯករាជ្យភាពរបស់ អ.វ.ត.ក ដែលជាស្ថាប័នតុលាការមួយ និងជាការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ។ លើសពីនេះទៅទៀត វាគំរាមកំហែងធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ភាពគួរឱ្យជឿជាក់បាននៃភស្តុតាង ហើយក៏គំរាមកំហែងដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់លោក នួន ជា ផងដែរ។ អាស្រ័យហេតុនេះ មេធាវីការពារក្តីសូមទទួចឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់វិធានការដាក់លាក់មួយចំនួន ដូចដែលបានសំណូមពរនៅក្នុងសំណើសុំនេះ ដោយចាត់ទុកបញ្ហានេះជាបញ្ហាបន្ទាន់មួយ ។

## II. អង្គហេតុពាក់ព័ន្ធ

២. [redacted] ("សាក្សី") ត្រូវបានការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") ស្តាប់ចម្លើយនៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨[២] និងស្តាប់ចម្លើយម្តងទៀតនៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩[៣]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨ ("កំណត់ហេតុ") មានសរសេរនៅត្រង់ផ្នែកពាក់ព័ន្ធ (មានបញ្ជាក់បន្ថែម) ថា៖

---

[១] *សូមមើល* ឯកសារលេខ **E-82** (នួន ជា) "សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៣៥" ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារ ERN 00680941-00680955 "សំណើសុំលើកទីមួយ"។

[២] [redacted]

[៣] [redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

## III. ច្បាប់ពាក់ព័ន្ធ

### ក. ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ

៣. វិធាន ៣៥(១) និង (២) នៃវិធានផ្ទៃក្នុងចែងនៅត្រង់ផ្នែកដែលពាក់ព័ន្ធថា៖

> អង្គជំនុំជម្រះវិសាមញ្ញអាចដាក់ទណ្ឌកម្ម ឬបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចនូវជនណាម្នាក់ដែលជ្រៀតជ្រែកដោយចេតនាពិតប្រាកដ ចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ រួមទាំងបុគ្គលដែលមានចែងដូចខាងក្រោម៖ [...] (ឃ)គំរាមកំហែង បំភិតបំភ័យ បង្ករបួសស្នាម ឬផ្ដល់សំណូក ឬក៏ជ្រៀតជ្រែកលើសាក្សីណាម្នាក់ ឬលើអ្នកដែលអាចក្លាយជាសាក្សីដែលកំពុងផ្ដល់ បានផ្ដល់ភស្តុតាងដល់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ, (ង)គំរាមកំហែង បំភិតបំភ័យ ឬសូកសំណូក ឬស្វែងរកវិធីគាបសង្កត់លើបុគ្គលដទៃទៀត ក្នុងបំណងទប់ស្កាត់បុគ្គលនោះមិនឱ្យអនុវត្តតាមដីការបស់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ, (ច)ញុះ ញង់ ឬប៉ុនប៉ងប្រព្រឹត្តអំពើណាមួយដូចមានចែងខាងលើ។
>
> នៅពេលដែលសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះមានហេតុផលជឿថា បុគ្គលណាម្នាក់អាចធ្លាប់បានប្រព្រឹត្តអំពើណាមួយដូចមានចែងក្នុងអនុវិធាន ១ ខាងលើ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអាច៖(ក) ចាត់ការជាមួយបញ្ហានេះជាបន្ទាន់, (ខ)ដឹកនាំការស៊ើប សួរបន្ថែមដើម្បីឱ្យដឹងប្រាកដ ថាតើមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ចាត់ការតាមនីតិវិធី, ឬ (គ)បញ្ជូនបញ្ហានេះទៅឱ្យអាជ្ញាធរមានសមត្ថកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា ឬអង្គការសហប្រជាជាតិ។

៤. អង្គបុរេជំនុំជម្រះ (“អ.ប.ជ”) បានកំណត់នូវបទដ្ឋាននៃការបង្ហាញភស្តុតាងខុសៗគ្នាចំនួនបីដែលពាក់ព័ន្ធនឹងនីតិវិធីនៅក្នុងវិធាន ៣៥។ ដែលក្នុងនោះបទដ្ឋានស្ដីពី “មូលហេតុអាចឱ្យជឿបាន” អនុវត្តចំពោះសំណើសុំនេះ។ អ.ប.ជ បានកំណត់បទដ្ឋាននេះថាមាន “លក្ខណៈវិនិច្ឆ័យទាបបំផុត”[៤]

---

[៤] *សូមមើល* ឯកសារលេខ **D-314/1/12**, (នួន ជា) “សាលដីកាលើកទីពីរលើបណ្ដឹងឧទ្ធរណ៍របស់លោក នួន ជា និងលោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី” ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ ERN 00600748-00600774 (សេចក្ដីសម្រេចលើកទីពីរទៅលើវិធាន ៣៥) កថាខណ្ឌ ៣៦ ដល់ ៣៧។

។

៥. ដើម្បីឲ្យសំណើសុំនេះសង្ខេបខ្លី[៥] មេធាវីការពារក្តីសូមធ្វើការយោង និងដាក់បញ្ចូលនូវសារណាលើអង្គច្បាប់មុនៗរបស់ខ្លួនស្តីពីវិធាន ៣៥[៦]។

## ខ. សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌

៦. វិធាន ២១(១) នៃវិធានផ្ទៃក្នុងចែងត្រង់ផ្នែកដែលពាក់ព័ន្ធថា៖

> ច្បាប់បង្កើត អ.វ.ត.ក វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ផលប្រយោជន៍របស់ [...] ជនត្រូវចោទ [...] និងដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព [...]។

## គ. ឯករាជ្យភាព និងអនាគតិរបស់តុលាការ

៧. ដើម្បីឲ្យសំណើសុំនេះសង្ខេបខ្លី[៧] មេធាវីការពារក្តីសូមធ្វើការយោង និងដាក់បញ្ចូលនូវសារណាលើអង្គច្បាប់មុនៗរបស់ខ្លួនស្តីពីវិធាន ទៅលើប្រធានបទនេះ[៨]។

---

[៥] អនុលោមតាមមាត្រា ៥.១ នៃសេចក្តីណែនាំអនុវត្ត មានការកម្រិតយ៉ាងតឹងរ៉ឹង ដោយតម្រូវឲ្យដាក់ឯកសារកម្រាស់តែ ១៥ ទំព័រ ជូនអង្គជំជម្រះសាលាដំបូង ។

[៦] សូមមើល ឯកសារលេខ **D-254**, (ន្ទូន ជា) "សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ" ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ ERN 00410838-00410848 (សំណើសុំឆ្នាំ ២០០៩) កថាខណ្ឌ ១០ ដល់ ១២។ ឯកសារលេខ**002/07-07-2010-ECCC-PTC(10)-1**, (នួន ជា) "សំណើលើកទីពីរសុំឲ្យបំពេញកិច្ចស៊ើបសួរ" ដាក់ជូន អបជ ចុះថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារ ERN 00549028-00549031 និង ដាក់នៅចំពោះមុខ កសចស ឯកសារលេខ **D-384.1**(នួន ជា) "ឧបសម្ព័ន្ធ ក សំណើលើកទីពីរសុំឲ្យបំពេញកិច្ចស៊ើបសួរ" ចុះថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១០ ERN 00549037-00549058 (សំណើសុំឆ្នាំ ២០១០) កថាខណ្ឌ ១៨ ដល់ ២៣។

[៧] *សូមមើល*ជើងទំព័រលេខ ០៥ ខាងលើ។

[៨] សំណើសុំឆ្នាំ ២០១០ កថាខណ្ឌ ២៤ ដល់ ២៦។

## ឃ. អំណាចរបស់អង្គជំនុំជម្រះសាលាដំបូង

៨. អនុលោមតាមវិធាន ៣៥(២) អង្គជំនុំជម្រះសាលាដំបូង មានអំណាចដឹកនាំការស៊ើបសួរបន្ថែម ក្នុងករណីមានហេតុផលជឿថា មានការជ្រៀតជ្រែកដោយចេតនាចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ។

## IV. ឧទ្ធិករណ៍

## ក. មានសញ្ញាណពិតនៃការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ

៩. ការលើកឡើងអំពីការគាបសង្កត់ និងការគំរាមកំហែង ដែលលេចចេញពីប្រតិចារឹកនៃកំណត់ហេតុស្ដាប់ចម្លើយសាក្សី (ដែលបានលើកឡើងក្នុងកថាខណ្ឌ ៣) បាននិយាយពីចំណុចនេះតែម្ដង[៩]។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីបង្ហាញហេតុផលឲ្យជឿបានថា បុគ្គលម្នាក់ (បុគ្គលច្រើននាក់) បានគំរាមកំហែងមកលើសាក្សីរូបនេះ និង/ឬ បានព្យាយាមប្រើឥទ្ធិពលមកលើរូបគាត់ និង/ឬ បានព្យាយាមកែប្រែដល់ខ្លឹមសារនៃចម្លើយរបស់គាត់ ដែលទង្វើបែបនេះ បានជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ[១០]។

១០. មេធាវីការពារក្ដីកត់សម្គាល់ឃើញថា វាមិនមែនជាការទទួលខុសត្រូវរបស់ខ្លួន ដើម្បីផ្ដល់ភស្តុតាងឥតប្រកែកបានចំពោះការជ្រៀតជ្រែកនេះទេ។ វាគ្រប់គ្រាន់ណាស់ទៅហើយ ដែលមេធាវីការពារក្ដីគ្រាន់តែបង្ហាញជូនអង្គជំនុំជម្រះសាលាដំបូងនូវ "ហេតុផលគួរឲ្យជឿបាន" ថា មាន"បុគ្គល"ខ្លះបានជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ ដែលនេះឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យ

[៩] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីបង្ហាញយ៉ាងច្បាស់ថា សក្ខីកម្មរបស់សាក្សីរូបនោះអាចត្រូវបានបញ្ចុះបញ្ចូល និង/ឬ ជះឥទ្ធិពលដោយការភ័យខ្លាច និង/ឬ ការព្រួយបារម្ភចំពោះសន្តិសុខ និងសុវត្ថិភាពផ្ទាល់ខ្លួន និង/ឬ ក្រុមគ្រួសាររបស់គាត់ ដែលហាក់មានន័យថា ការសន្យាមិនត្រឹមត្រូវអំពីការដោះលែងពីពន្ធនាគារក្នុងពេលឆាប់ៗ ឬ (ផ្ទុយទៅវិញ) ការគំរាមកំហែងអំពីការឃុំខ្លួនជាបន្តទៅទៀត អាចជះឥទ្ធិពលយ៉ាងខ្លាំងដល់ខ្លឹមសារនៃចម្លើយរបស់សាក្សីរូបនេះ។

[១០] (ជាថ្មីម្ដងទៀត) មេធាវីការពារក្ដីយល់ឃើញថា មានហេតុផលអាចឲ្យជឿបានថា ការជ្រៀតជ្រែកបែបនេះកើតចេញពីរាជរដ្ឋាភិបាលកម្ពុជា។ ប៉ុន្តែ បញ្ហានេះមិនពាក់ព័ន្ធទៅនឹងលទ្ធផលនៃនីតិវិធីដែលមានចែងក្នុងវិធាន ៣៥ នោះទេ៖ ទម្រង់*ណាមួយ*នៃការជ្រៀតជ្រែកមកលើសាក្សី និង/ឬ ចម្លើយសាក្សី អាចត្រូវបានឆ្លើយតបទៅវិញទាំងបង្ខំតាមរយៈតុលាការ ដោយមិនគិតពីប្រភពនៃការជ្រៀតជ្រែកនោះឡើយ។

ក្នុងកម្រិតទាបបំផុត[១១]។ ហេតុដូច្នេះ បទដ្ឋាននៃការបង្ហាញភស្តុតាងសម្រាប់ការអនុវត្តវិធាន ៣៥ ត្រូវបានមេធាវីការពារក្តីបំពេញរួចទៅហើយ។

## ខ. អង្គជំនុំជម្រះសាលាដំបូងត្រូវតែស៊ើបអង្កេត នៅពេលដែលសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ត្រូវបានគំរាមកំហែង និង/ឬរំលោភបំពាន

១១. អនុលោមតាមវិធាន ២១ សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៣៥ គឺជាសំណើសុំដែលត្រូវតែធ្វើជាដាច់ខាត នៅពេលដែលសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនជាប់ចោទត្រូវបានគេគំរាមកំហែង ឬរំលោភបំពាន។ វាច្បាស់ហើយថា ការគំរាមកំហែង ឬការណែនាំ *ណាមួយ*ដល់សាក្សី គឺជាការរំលោភយ៉ាងខ្លាំងដល់សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនជាប់ចោទ។ វាកាន់តែពិតជាងនេះទៅទៀត ប្រសិនបើសាក្សីបែបនេះផ្តល់ចម្លើយដែលអាចត្រូវបានពិចារណាដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះសាលាដំបូងថា ជាភស្តុតាងដាក់បន្ទុកមកលើជនជាប់ចោទនោះ។

១២. ដូចដែល អ.ប.ជ បានសម្រេចថា៖

> វិធាន ៣៥ ត្រូវបានដាក់បញ្ចូលទៅក្នុងវិធានផ្ទៃក្នុង ដើម្បីធ្វើជាយន្តការមួយធានាអំពីសុចរិតភាពនៃកិច្ចដំណើរការរបស់តុលាការ ទាំងនៅដំណាក់កាលស៊ើបអង្កេត និងនៅដំណាក់កាលជំនុំជម្រះ។ សុចរិតភាពនៃដំណើរការនីតិវិធី ត្រូវបានធានាតាមរយៈការអនុវត្តវិធាននេះតាមផ្លូវតុលាការ នៅពេលដែល ស.ច.ស ឬ អង្គជំនុំជម្រះចាត់ទុកថា សកម្មភាពរបស់បុគ្គលណាម្នាក់ បានគំរាមកំហែងដល់កិច្ចការរដ្ឋបាលរបស់តុលាការ។ ទោះបីជាមិនមានផលប៉ះពាល់ភ្លាមៗដល់សេចក្តីសម្រេចលើការស៊ើបអង្កេត និងសេចក្តីសម្រេចរបស់តុលាការក៏ដោយ ក៏ការអនុវត្តបទប្បញ្ញត្តិនេះ គឺជាយន្តការមួយរារាំងបុគ្គលដទៃទៀត ដែលអាចត្រូវបានគេមើលឃើញថា អាចជ្រៀតជ្រែកដល់ដំណើរការនីតិវិធី។ វិធាននេះក៏ជំរុញឱ្យមានការជឿទុកចិត្តពីសំណាក់បុគ្គលដែលបានផ្តល់ចម្លើយរួចហើយ និងបុគ្គលដែលអាចយល់ថា នឹងមកផ្តល់ភស្តុតាងដែលធ្វើឱ្យបុគ្គលទាំងនេះជឿជាក់ថា ស.ច.ស និង/ឬ អង្គជំនុំជម្រះ នឹងចាត់វិធានការដោយមិនមានការស្ទាក់ស្ទើរចំពោះអ្នកមានបំណងរារាំង ឬជ្រៀតជ្រែកដល់ការចូលរួមរបស់ពួកគេជាមួយនឹង អ.វ.ត.ក។ ប្រសិនបើអនុវត្តបែបនេះមែន វានឹងធានាឱ្យមានភាពជឿជាក់លើកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ

[១១] ទោះបីជា (ខ្លឹមសារនៃចម្លើយរបស់) [redacted] ពិតជាត្រូវបានធ្វើឱ្យប៉ះពាល់ដោយការគាបសង្កត់ពីខាងក្រៅឬអត់នោះ គឺមិនពាក់ព័ន្ធនោះទេ នៅពេលពិចារណាអំពីសំណើសុំនេះ។ វិធាន ៣៥(១)(ឆ) ក៏និយាយតែអំពីចេតនាក្នុងការជ្រៀតជ្រែកនេះដែរ។

អ.វ.ត.ក ទាំងក្នុងកម្រិតអន្តរជាតិ និងកម្រិតជាតិ[១២]។

១៣. អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូង មានកាតព្វកិច្ចស៊ើបអង្កេត និងដោះស្រាយការជ្រៀតជ្រែកបែបនេះប្រកបដោយប្រសិទ្ធភាព[១៣]។

## គ. ភាពអាចឲ្យជឿជាក់បាននៃភស្តុតាង ត្រូវបានប៉ះពាល់

១៤. មេធាវីការពារក្តី មានផលប្រយោជន៍យ៉ាងច្បាស់នៅក្នុងការពិនិត្យអំពីភាពអាចឲ្យជឿជាក់បានទៅលើភស្តុតាងដែលអាចត្រូវបានប្រើប្រាស់ប្រឆាំងនឹងជនជាប់ចោទ។ មេធាវីការពារក្តីបានសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការធានាឲ្យមានជំនឿទុកចិត្តទៅលើភស្តុតាង[១៤]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា "ការពិនិត្យមើលពីភាពអាចឲ្យជឿជាក់បាននៃ [សម្ភារៈដែលដាក់ជូននៅសវនាការគឺជា] បុរេលក្ខខណ្ឌដើម្បីយកមកធ្វើជាភស្តុតាង"[១៥]។ អាស្រ័យហេតុនេះ ភស្តុតាងត្រូវមានភាព

---

[១២] ឯកសារលេខ **D314/7** "សេចក្តីសម្រេចជាសម្ងាត់ទៅលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឲ្យកោះហៅសាក្សី" ចុះថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ ERN 00527392-00527420 កថាខណ្ឌ ៣៨។

[១៣] លើសពីនេះទៅទៀត មិនមានហេតុផលដែលអាចសន្មតបានថា មានតែសាក្សីរូបនេះទេដែលត្រូវបានគេគំរាមកំហែង និង/ឬបង្ក្រាបបញ្ហា បើពិចារណាទៅលើលំនាំនៃការជ្រៀតជ្រែកទៅក្នុងកិច្ចការរបស់ អ.វ.ត.ក ដែលមានជាយូរមកហើយ (សូមមើលសំណើមុនៗរបស់លោក នួន ជា សុំឲ្យបំពេញកិច្ចស៊ើបសួរ)។ ហេតុដូច្នេះ ការស៊ើបអង្កេតដែលធ្វើឡើងដោយ អ.ជ.ស.ជ មិនគួរមានកម្រិតទៅលើវិសាលភាពខ្លាំងពេកនោះទេ ហើយក៏ត្រូវដោះស្រាយការគាបសង្កត់ (ប្រហែលជា) ដែលបានប្រើប្រាស់ទៅលើសាក្សីដទៃទៀតផងដែរ ប្រសិនបើ អ.ជ.ស.ជ ទទួល ឬបានទទួលសញ្ញាណថា ការគាបសង្កត់បែបនេះត្រូវបានប្រើប្រាស់មកលើសាក្សីមែននោះ។

[១៤] *សូមមើល* ឯកសារ **D-336** "សំណើលើកទី២២ សុំឲ្យបំពេញកិច្ចស៊ើបសួរ" ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១០ កថាខណ្ឌ ១៦ ERN 00436437-00436445។ ឯកសារលេខ **D-319** "សំណើលើកទី២០ សុំឲ្យបំពេញកិច្ចស៊ើបសួរ" ថ្ងៃទី១៣ មករា ២០១០ ERN 00432928-00432937 កថាខណ្ឌ១៦។ *សូមមើល* ឯកសារលេខ **D-253** "សំណើលើកទីដប់ប្រាំមួយសុំឲ្យបំពេញកិច្ចស៊ើបសួរ" ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ ERN ០០៤១០៨០៣-០០៤១០៨១០ និង ឯកសារលេខ **D-265** "សំណើទីដប់ប្រាំពីរសុំឲ្យបំពេញកិច្ចស៊ើបសួរ" ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៩ ឯកសារERN ០០៤១១៣៤៨-០០៤១១៣៥៧ ។

[១៥] សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ ឯកសារលេខ **E-5/10/5** សាធារណៈ "សេចក្តីសម្រេចលើឃុតខ្សែភាពយន្តដែលបានដាក់ដោយសហព្រះរាជអាជ្ញា និងលើសាក្សី CP3/3/2 និង CP3/3/3" ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៩ ឯកសារ ERN 00356281-00356285 កថាខណ្ឌ ៨។

អាចឲ្យជឿជាក់ ដើម្បីអាចឲ្យទទួលយកបាន[១៦]។

១៥. ភាពអាចឲ្យជឿជាក់បាននៃសក្ខីកម្មរបស់សាក្សី អាចនឹងត្រូវបាត់បង់ទៅវិញ តាមរយៈការបង្ហាញឲ្យឃើញនូវការគំរាមកំហែង និងការបង្ខាប់ ដែលក្លាយជាភាពជាក់ស្តែងនៅពេលមើលកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី។ វាជាភារកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការសម្រេចអំពីវិសាលភាពនៃការជ្រៀតជ្រែក ប្រភពនៃការជ្រៀតជ្រែក គោលបំណងជាក់ស្តែងនៃការជ្រៀតជ្រែក និងផលប៉ះពាល់ទៅលើខ្លឹមសារសំខាន់ៗនៃកំណត់ហេតុនេះ។ ដើម្បីសម្រេចបានប្រសិទ្ធភាពនោះ ការស៊ើបអង្កេតនេះគួរត្រូវធ្វើឡើងឲ្យបានប្រសើរបំផុត នៅមុនសវនាការបឋម។

## ឃ. ការស្តាប់ចម្លើយសាក្សីនៅពេលសវនាការ មិនមែនជាជម្រើសមួយគ្រប់គ្រាន់នោះទេ

១៦. ការស្តាប់ចម្លើយ [redacted] នៅក្នុងពេលសវនាការមិនមែនជាជម្រើសមួយគ្រប់គ្រាន់សម្រាប់ការផ្តួចផ្តើមនៃនីតិវិធីនៅក្នុងវិធាន ៣៥ នោះទេ។ ការស្តាប់ចម្លើយសាក្សីនៅក្នុងអំឡុងសវនាការអាចមានជោគជ័យបំផុត ដើម្បីលុបបំបាត់ការមន្ទិលសង្ស័យទៅលើភាពឲ្យជឿជាក់បាននៃសាក្សី និងចម្លើយរបស់គាត់ ប៉ុន្តែ ការចោទសួរនឹងស្ថិតនៅលើការលាតត្រដាង ការបង្ការ និងការដោះស្រាយឲ្យមានប្រសិទ្ធភាពអំពីការជ្រៀតជ្រែកពីខាងក្រៅ ដែលមេធាវីការពារក្តីជឿជាក់ថាបានកើតមានឡើងមែននោះ។ ការលាតត្រដាង ការបង្ការ និងការដោះស្រាយប្រកបដោយប្រសិទ្ធភាពអំពីការជ្រៀតជ្រែកពីខាងក្រៅ តម្រូវឲ្យមានការស៊ើបអង្កេតមួយត្រឹមត្រូវទៅលើការជ្រៀតជ្រែកបែបនេះ និងការដាក់ទណ្ឌកម្មក្នុងពេលជាមួយគ្នានេះ។ លុះណាតែវិធីបែបនេះនឹងមានដំណើរការ "ទើប

---

[១៦] *សូមមើល* ឯកសារលេខ **D-336** (នួន ជា) "សំណើលើកទី ២២ សុំឲ្យបំពេញកិច្ចស៊ើបសួរ" ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១០ ឯកសារ ERN 00436437-00436445 ("សំណើសុំលើកទី ២២") កថាខណ្ឌ ៦ និងឯកសារលេខ **D-319** (នួន ជា) "សំណើលើកទី ២០ សុំឲ្យបំពេញកិច្ចស៊ើបសួរ" ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ ឯកសារ ERN 00432928-00432937 ("សំណើសុំលើកទី ២០) កថាខណ្ឌ ៦។

អាចធ្វើឲ្យអ្នកដែលអាចប្រើឥទ្ធិពលមកលើដំណើរការក្តី មានការរាងចាលទៅបាន"[១៧]។ ការគ្រាន់តែចោទសួរទៅលើសាក្សីនៅពេលសវនាការ នឹងពិបាកសម្រេចទៅបានណាស់។ លើសពីនេះទៅទៀត ការស៊ើបអង្កេតដោយអនុលោមតាមវិធាន ៣៥ គឺជាការខានពុំបានដើម្បីផ្តល់ឲ្យមេធាវីកាពារក្តីនូវមធ្យោបាយដែលតម្រូវឲ្យមាន សម្រាប់សួរសាក្សីក្នុងអំឡុងពេលសវនាការ។មេធាវីការពារក្តីត្រូវទទួលបាន[១៨] ការរៀបរាប់ដំណើររឿងឲ្យបានច្បាស់លាស់នូវអ្វីដែលបានកើតឡើងពិតប្រាកដ ដើម្បីបង្កលក្ខណៈឲ្យមានការចោទសួរសាក្សីប្រកបដោយប្រសិទ្ធភាព។ មានតែការស៊ើបអង្កេតជាមុនដោយអង្គជំនុំជម្រះសាលាដំបូងទេ ទើបអាចសម្រេចចំណុចនេះទៅបាន[១៩]។

## ខ. ការធ្វើសេចក្តីសម្រេចជាបន្ទាន់ទៅលើសំណើសុំនេះ គឺជាការចាំបាច់

១៧. ដូចដែលបានលើកឡើងក្នុងសំណើសុំនេះ ក៏ដូចជានៅក្នុងសារណាមុនៗរបស់មេធាវីការពារក្តី ការជ្រៀតជ្រែកហាក់ដូចជាមានលក្ខណៈទូលំទូលាយ និងមានជាយូរមកហើយ។ នៅពេលពិចារណាឲ្យបានដិតដល់ មិនមានហេតុផលដ៏ល្អណាមួយដែលអាចឲ្យជឿបានថា ការជ្រៀតជ្រែកមិនបន្តមាននៅពេលបច្ចុប្បន្ននោះទេ។ ស្ថានភាពនេះមិនតម្រូវអ្វីក្រៅតែពីការចាត់វិធានការ *ជាបន្ទាន់* ដោយអង្គជំនុំជម្រះសាលាដំបូងនោះទេ ហើយក៏ដើម្បីទប់ស្កាត់កុំឲ្យមានការជ្រៀតជ្រែកមកលើ

---

[១៧] ឯកសារលេខ **D314/7** "សេចក្តីសម្រេចជាសម្ងាត់ទៅលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឲ្យកោះហៅសាក្សី" ចុះថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ ERN 00527392-00527420 កថាខណ្ឌ ៣៨។

[១៨] ជាថ្មីម្តងទៀត ដូចបានដឹងច្បាស់ហើយថា មេធាវីការពារក្តីមិនមែនត្រឹមតែមិនមានអំណាច ឬធនធានដើម្បីធ្វើការស៊ើបអង្កេតដោយខ្លួនឯងប៉ុណ្ណោះទេ តែមេធាវីការពារក្តីត្រូវបានហាមឃាត់យ៉ាងច្បាស់ក្រឡែតមិនឲ្យធ្វើការស៊ើបអង្កេតបែបនេះទេ។

[១៩] សម្រាប់ហេតុផលដូចគ្នានេះដែរ សេចក្តីសម្រេច និងការអនុវត្តទៅលើសំណើសុំនេះ មិនគួរពន្យារពេល *រហូតដល់ក្រោយពី* សាក្សីបានផ្តល់សក្ខីកម្មនៅក្នុងពេលសវនាការសាធារណៈនោះទេ។ សញ្ញាណនៃការជ្រៀតជ្រែកមានច្រើន និងច្បាស់លាស់ ហេតុដូច្នេះមិនមានហេតុផលអ្វីដែលត្រូវពន្យារការផ្តួចផ្តើមស៊ើបអង្កេតនោះឡើយ។ លើសពីនេះទៀត ដូចដែលបានជំទាស់តវ៉ារួចមកហើយ ដើម្បីធ្វើការចោទសួរសាក្សីឲ្យបានគ្រប់គ្រាន់ និងប្រកបដោយប្រសិទ្ធភាពនៅពេលសវនាការ នោះការស៊ើបអង្កេតដែលត្រូវតែមានជាមុន គឺជាលក្ខខណ្ឌបឋម។ ដូច្នេះ ការពន្យារការស៊ើបអង្កេតដោយអនុលោមតាមវិធាន ៣៥ រហូតដល់ក្រោយការស្តាប់ចម្លើយសាក្សីនៅពេលសវនាការ នឹងគ្រាន់តែបង្កើនភវនីយភាពដែលថា សាក្សីនឹងត្រូវការស្តាប់ចម្លើយសាក្សីលើកទីពីរ ដែលនេះគ្រាន់តែជាការធ្វើឲ្យបាត់បង់ពេលវេលា និងធនធានដ៏មានតម្លៃរបស់សាលាក្តីនេះតែប៉ុណ្ណោះ។

ការផ្តល់ចម្លើយពីសំណាក់សាក្សីទៀតផងដែរ។ លើសពីនេះទៅទៀត ការរំលោភបែបនេះត្រូវតែប្រមូលចងក្រងឲ្យបានត្រឹមត្រូវ *ទៅមុខ*សវនាការដើម្បីអាចឲ្យអង្គជំនុំជម្រះសាលាដំបូង ផ្តល់ដំណោះស្រាយឲ្យបានគ្រប់គ្រាន់នៅក្នុងពេលសវនាការ និងដើម្បីអនុញ្ញាតឲ្យមេធាវីការពារក្តីមានឱកាសប្រកបដោយអត្ថន័យធ្វើការជំទាស់ទៅនឹងការជ្រៀតជ្រែក និង/ឬ ការស៊ើបអង្កេត (ដែលបានអះអាង) ច្បាស់លាស់ណាមួយទៅបាន។ ដោយសំអាងទៅលើមូលហេតុទាំងនេះ មេធាវីការពារក្តី សំណូមពរឲ្យចេញសេចក្តីសម្រេចទៅលើសំណើសុំនេះក្នុងរយៈពេលមួយខែ។

## V. សំណូមពរ

១៨. មេធាវីការពារក្តីយល់ឃើញថា មានតែការស៊ើបសួរឲ្យបានហ្មត់ចត់តែប៉ុណ្ណោះ ទើបអាចធ្វើការស៊ើបអង្កេត និងដោះស្រាយយ៉ាងមានប្រសិទ្ធភាព ចំពោះការជ្រៀតជ្រែកដោយចេតនាទៅលើ (ការផ្តល់ចម្លើយ) របស់ [redacted] ទៅបាន (និងប្រហែលជាទៅលើសាក្សីដទៃទៀតផងដែរ)។ ហេតុដូច្នេះ តាមរយៈសំណើសុំនេះ មេធាវីការពារក្តីសំណូមពរឲ្យអង្គជំនុំជម្រះសាលាដំបូងចាត់វិធានការទៅលើសកម្មភាពដូចមានខាងក្រោម ជាបញ្ហាបន្ទាន់៖

ក. ស្តាប់ចម្លើយ [redacted] ឡើងវិញ[២០]។

ខ. ស្តាប់ចម្លើយប្អូនស្រី និងសាច់ញាតិរបស់ [redacted]។

គ. ស្តាប់ចម្លើយ "មេៗ" ដូចដែលបានលើកឡើងនៅក្នុងកំណត់ហេតុនៃស្តាប់ចម្លើយរបស់ [redacted]។

ឃ. ស្តាប់ចម្លើយ ក្មួយស្រី និងប្រពន្ធរបស់ [redacted]។

ង. ចាត់វិធានការផ្សេងទៀត និងស្វែងរកដំណឹងជាតម្រុយណាមួយ ដើម្បីធ្វើការស៊ើបអង្កេតឲ្យមានប្រសិទ្ធភាពទៅលើសញ្ញាណនៃការជ្រៀតជ្រែកទៅលើ (ចម្លើយដែលផ្តល់ដោយ) [redacted]

---

[២០] មេធាវីការពារក្តីយល់ឃើញថា *យ៉ាងហោចណាស់*ក៏សំណួរដែលបានលើកឡើងដោយមេធាវីការពារក្តី ដែលជាផ្នែកមួយនៃសំណើសុំលើកទី ២២ របស់ខ្លួននោះ (ពាក់ព័ន្ធទៅនឹងការជ្រៀតជ្រែកនេះ) គួរត្រូវបានយកមកចោទសួរដែរ។ *សូមមើល* សំណួរដែលត្រូវសួរទៅកាន់សាក្សី ដែលបានដាក់ដោយមេធាវីការពារក្តី" [ឯកសារលេខ **D-336.1** (នួន ជា) "ឧបសម្ព័ន្ធ ក៖ សំណួរដែលត្រូវសួរសាក្សី" ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១០ ឯកសារ ERN 00436459-00436474]។

[redacted]។

ច. ចាត់វិធានការផ្សេងទៀត និងស្វែងរកដំណើងជាតម្រុយណាមួយ ដើម្បីធ្វើការស៊ើបអង្កេតឱ្យមានប្រសិទ្ធភាពទៅលើសញ្ញាណនៃការជ្រៀតជ្រែកដោយចេតនា ដែលមិនទាន់បានដឹង ដោយអនុវត្តការស៊ើបអង្កេតស្របតាមវិធាន ៣៥។

ឆ. ដាក់ទណ្ឌកម្មយ៉ាងមានប្រសិទ្ធភាពចំពោះបុគ្គលទាំងឡាយណា ដែលអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា មានការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលដ៏ត្រឹមត្រូវរបស់តុលាការ ក្នុងគោលបំណងទប់ស្កាត់កុំឱ្យមានការជ្រៀតជ្រែកដល់ចម្លើយ ដែលផ្តល់ដោយសាក្សីនានា (ផងដែរ)។

ជ. ចេញសេចក្តីសម្រេចទៅលើសំណើសុំនេះក្នុងរយៈពេលមួយខែ បន្ទាប់ពីពេលដាក់ឯកសារនេះរួចមក។

**សហមេធាវីការពារក្តីរបស់លោក នួន ជា**

p.p.

**Michiel PESTMAN** **និង** **Victor KOPPE**